## ការឈ្លានពាន (Aggression)

ពាក្យនេះ ត្រូវបានផ្តល់សញ្ញាណក្នុងមាត្រា១០ នៃ អនុសញ្ញា ស្តីពី League of Nations ដែលទាមទារឲ្យសមាជិកគោរព និងរក្សា ព្រមទាំងប្រឆាំងនឹងការឈ្លានពានពីខាងក្រៅ លើបូរណភាពដែនដី និង ឯករាជ្យភាពនយោបាយ។ គោលបំណង ចែងក្នុងមាត្រា១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីបង្ក្រាបទង្វើឈ្លានពាន ដែលនាំឲ្យប៉ះសន្តិភាពពិភពលោក និងផ្ទុកផ្តាក់ការងារសន្តិសុខ ជូនដល់ក្រុមប្រឹក្សាសន្តិសុខ (មាត្រា៣៩)។ ក្នុងឆ្នាំ១៩៤៥ តុលាការយោធាអន្តរជាតិ (International Military Tribunal) ចាត់ទុកសង្គ្រាមឈ្លានពាន (war of aggression) ជាបទល្មើស ប្រឆាំងនឹងសន្តិភាព ដែលនាំឲ្យបុគ្គលទទួលខុសត្រូវ។ ឆ្នាំ១៩៧៤ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ បានព្យាយាមផ្តល់ន័យថា៖ ការប្រើកម្លាំងទ័ព ដោយរដ្ឋប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពដែនដី ឯករាជ្យភាពនយោបាយរបស់រដ្ឋផ្សេង ដែលផ្ទុយនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

ការប្រើកម្លាំងទ័ពជា ភស្តុតាងដំបូង និងច្បាស់ក្រឡែតនៃវត្តមាននៃការឈ្លានពាន។ ទោះបីជាយ៉ាងនេះក្តី មិនមែនគ្រប់ការប្រើកម្លាំង សុទ្ធតែជាការឈ្លានពានទេ។ ក្រុមប្រឹក្សាសន្តិសុខ ជាស្ថាប័នកំណត់ថា ទង្វើណាមួយ ជាការឈ្លានពាន (EDIL, Aggression, 2009, p. 18)។

**ខ្លឹមសារបន្ថែម៖** ឆ្នាំ ១៩៩៨ លក្ខន្តិកៈទីក្រុងរ៉ូម បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court) បានដាក់បទឈ្លានពាន ក្នុងសមត្ថកិច្ចរបស់តុលាការនេះ ដែលនាំឲ្យបុគ្គលដូចជាមេដឹកនាំរដ្ឋ ដែលចូលរួមក្នុងទង្វើឈ្លានពាន នឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល (មាត្រា៥)។ ទោះបីជាយ៉ាងនេះក្តី ដោយសារបញ្ហាផ្លូវច្បាប់ និងការជំទាស់ពីរដ្ឋមួយចំនួន បទប្បញ្ញត្តិពាក់ព័ន្ធ មិនទាន់អាចអនុវត្តបាន ដោយរង់ចាំ ការកំណត់និយមន័យ នៃបទឈ្លានពានឲ្យជាក់លាក់។ នាពេលនេះ បទប្បញ្ញត្តិមានជាធរមាន អាចអនុវត្តបានហើយ ក៏ប៉ុន្តែមិនទាន់មានការចោទប្រកាន់នូវបទឈ្លានពានណាមួយឡើយនៅមុខ ICC។